# ឱកាសការងារ

**គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី** គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំៗនៅក្នុងប្រទេសកម្ពុជា។ អេ អឹម ខេ បានផ្តល់សេវាកម្មជូនអតិថិជនជាង១,០០០,០០០នាក់ ដែលមានបុគ្គលិកសរុបជាង ៣,០០០នាក់ ហើយនឹងមានការិយាល័យសាខានៅគ្រប់ខេត្តក្រុងទូទាំងប្រទេស។

**មុខតំណែង:** មន្ត្រីទំនាក់ទំនងលក់ (ចំនួន ៨នាក់)

**ទីតាំងត្រូវបំពេញការងារ:** ប្រចាំនៅសាខាខេត្តបន្ទាយមានជ័យ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តសៀមរាប ខេត្តបាត់ដំបង និងសាខាភ្នំពេញ

**កាលបរិច្ឆេទឈប់ទទួលពាក្យ:** ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៩

## ភារៈកិច្ចនិងការទទួលខុសត្រូវ:

- លក់សេវាកម្មភតិសន្យាហិរញ្ញវត្ថុ
- បង្កើនចំនួនដៃគូសហការអាជីវកម្ម រក្សាទំនាក់ទំនងល្អជាមួយដៃគូរអាជីវកម្ម និងបង្កើនការពេញចិត្តពីដៃគូរអាជីវកម្ម
- វាយតម្លៃបឋមលើអតិថិជនភតិសន្យាហិរញ្ញវត្ថុ ដំណើរការពាក្យស្នើសុំភតិសន្យាហិរញ្ញវត្ថុប្រកបដោយគុណភាព
- គ្រប់គ្រងសម្ភារៈដែលត្រូវដាក់តាំងនៅដៃគូរហាងអាជីវកម្ម
- ប្រមូលព័ត៌មានត្រឡប់ពីដៃគូរអាជីវកម្ម និងអតិថិជនដើម្បីធ្វើអោយសេវាកម្មរបស់ អេអឹមខេ កាន់តែល្អប្រសើរ
- ប្រមូលនិងដឹងពីស្ថានភាពទីផ្សារនិងគូប្រកួតប្រជែងក្នុងកំណត់វិធីសាស្ត្រចូលទៅកាន់ទីផ្សារ

## កំរិតវប្បធម៌និងបទពិសោធន៍:

- មានកំរិតវប្បធម៌យ៉ាងតិចចប់ថ្នាក់ទី១២ ឬសិក្សាថ្នាក់បរិញ្ញាប័ត្រ
- មានបទពិសោធន៍តិចតួចទាក់ទងជាមួយនឹងការលក់ ឬមានបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុកាន់តែប្រសើរ
- មានចរិកលក្ខណល្អនិង ស្មោះត្រង់
- មានការតាំងចិត្តខ្ពស់ក្នុងការបំពេញការងារ

**អេ អឹម ខេ** ធ្វើការផ្តល់ប្រាក់បៀវត្សដោយមានការប្រកួតប្រជែងបំផុតទៅដល់បេក្ខជន។ បុគ្គលិកនឹងទទួលបានការតម្លើងប្រាក់បៀវត្ស បន្ទាប់ពីចប់ការសាកល្បងការងារនិងមានកំណើនទៀងទាត់ប្រចាំឆ្នាំ។ ទទួលបានប្រាក់ឧបត្ថម្ភពេលចូលឆ្នាំខ្មែរនិងបុណ្យភ្ជុំបិណ្ឌ ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ប្រាក់សោធននិវត្តន៍ប្រាក់ឧបត្ថម្ភសម្រាប់បុគ្គលិកបម្រើការងារយូរ ប្រាក់ឧបត្ថម្ភសម្រាប់បុគ្គលិកចូលនិវត្តន៍ ផ្តល់ការធានារ៉ាប់រងសុខភាព១០០% ដោយមិនកំណត់សម្រាប់បុគ្គលិក រួមទាំងអ្នកក្នុងបន្ទុក ផ្តល់ការធានារ៉ាប់រង២៤ម៉ោងទៅលើគ្រោះថ្នាក់ដល់បុគ្គលិក និង ផ្តល់ថ្លៃព្យាបាលជំងឺទៅក្រៅប្រទេស ផ្តល់កម្ចីគេហដ្ឋានថ្មី ដោយអត្រា ការប្រាក់ត្រឹមតែ៥%ក្នុងមួយឆ្នាំ ប្រាក់កម្ចីសិក្សាក្នុងអត្រាការប្រាក់ត្រឹមតែ២%ក្នុងមួយឆ្នាំ ផ្តល់ការឈប់សម្រាកដោយមាន ប្រាក់ឈ្នួលរហូតដល់ទៅ៦ខែ សម្រាប់បុគ្គលិកមានជំងឺ ផ្តល់ប្រាក់ឧបត្ថម្ភលើការសម្រាលបុត្រ និងអាចទទួលបានប្រាក់បៀវត្សរហូតដល់ ១៧០%ក្នុងមួយខែក្នុងពេលសម្រាកមាតុភាព ការឈប់សម្រាកដោយមានប្រាក់ ឈ្នួលរហូតដល់ទៅ១៨ថ្ងៃក្នុង១ឆ្នាំ ការកសាងសមត្ថភាព ផ្អែកលើតម្រូវការជាក់ស្តែង និងមានលក្ខខណ្ឌការងារស្រប ទៅតាមច្បាប់ការងារនៃប្រទេសកម្ពុជា។

បេក្ខជនដែលមានចំណាប់អារម្មណ៍សូមផ្ញើប្រវត្តិរូបសង្ខេបនិងពាក្យសុំបំពីការងារ(CV and Cover Letter)មកកាន់ការិយាល័យ អេ អឹម ខេគ្រប់សាខា និង អនុសាខា រឺការិយាល័យកណ្តាល អគារលេខ២៨៥ មហាវិថី យោធពលខេមរភូមិន្ទ (ផ្លូវ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញឬតាមរយ:
E-mail: job@amkcambodia.com

**ភ្ជាប់ជាមួយ:**

- ថតចំលងសញ្ញាប័ត្រដែលទទួលបាន ឬលិខិតបញ្ជាក់ពីសាលា / សាកលវិទ្យាល័យ
- ថតចំលងអត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងលិខិតបញ្ជាក់កំណើត
- ថតចំលងតារាងពិន្ទុបញ្ជាក់ការសិក្សាពីសាកលវិទ្យាល័យ

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកទូរស័ព្ទលេខ:០២៣ ៩៩៣ ០៦២/០២៣ ២២៤ ៧៦៣ ឬគេហទំព័រ: www.amkcambodia.com

**អេ អឹម ខេ** ផ្តល់ឱកាសស្មើៗគ្នាសំរាប់បេក្ខជនទាំងអស់។ ស្ត្រីនិងជនពិការត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យ។